## ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
## អភិបូជាអធិដ្ឋានពេញមួយយប់សម្រាប់ការត្រាស់ហៅនៅអារាមតាមែល
## កំពង់ស្ពឺ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០
## នៅក្នុងទុក្ខលំបាកយើងរកឃើញពន្លឺនៃជំនឿ

**អត្ថបទទី១៖ ពង្សាវតារក្សត្រទី១ ២,១-៤.១០-១២**

បិតាជិតលាចាកលោកនេះហើយ ចូរបុត្រមានចិត្តក្លាហានឲ្យសមជាមនុស្សពេញលក្ខណៈ។ ១ពង្ស ២,២

**អត្ថបទទី២៖ របាក្សត្រទី១ ២៩,១០-១២**

ដោយសារព្រះបារមីរបស់ព្រះអង្គ ព្រះអង្គអាចពង្រីក និងពង្រឹងអ្វីៗទាំងអស់ឲ្យបានរឹងមាំ។ ១របា ២៩,១២ខ

**ដំណឹងល្អ៖ ម៉ាកុស ៦,៧-១៣**

ពេលនោះ ព្រះអង្គត្រាស់ហៅសាវ័កទាំងដប់ពីររូបមក រួចទ្រង់ចាត់គេពីរៗនាក់ឲ្យទៅ ទាំងប្រទានឲ្យគេមានអំណាចដេញលើវិញ្ញាណអាក្រក់ផង។ មក ៦,៧

បងប្អូនជាទីស្រឡាញ់!

អធិដ្ឋានសម្រាប់ការត្រាស់ហៅថ្ងៃនេះ យើងមានសន្តប៉ូលមីគីដែលជាគំរូដើម្បីបំភ្លឺនៅក្នុងអត្ថបទដែលយើងបានស្តាប់។ អត្ថបទទី១ "**បិតាជិតលាចាកលោកនេះហើយ ចូរបុត្រមានចិត្តក្លាហាន ឲ្យសមជាមនុស្សពេញលក្ខណៈ ចូរមានចិត្តស្មោះត្រង់នឹងព្រះអម្ចាស់ជាព្រះរបស់បុត្រ ចូរប្រព្រឹត្តតាមព្រះហឫទ័យរបស់ព្រះអង្គជានិច្ច ហើយកាន់តាមក្រឹត្យវិន័យ តាមបញ្ញា តាមច្បាប់ និងតាមដំបូន្មាន ដែលមានចែងទុកក្នុងវិន័យរបស់លោកម៉ូសេ ដើម្បីឲ្យបុត្រមានជោគជ័យ ក្នុងគ្រប់កិច្ចការដែលបុត្រធ្វើ និងគ្រប់ទីកន្លែងដែលបុត្រទៅ**"។ ពាក្យនេះជាពាក្យមរតក ដែលអាចជួយឲ្យយើងមានសេចក្តីក្លាហាន ចិត្តស្មោះត្រង់ ធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់... ដើម្បីធ្វើជាមនុស្សដ៏ពេញលក្ខណៈ ដើម្បីពោរពេញដោយសុភមង្គលដែលព្រះជាម្ចាស់ប្រទានឲ្យសម្រាប់អ្នកដែលធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។

នៅឆ្នាំ១៥៨០ជាង ប្រទេសជប៉ុនមានសន្តហ្វ្រង់ស្វ័រសាវីយេ ដែលបានទៅប្រកាសដំណឹងល្អឲ្យប្រជាជនជប៉ុនមួយចំនួនភ្ញាក់ស្មារតីកែប្រែចិត្តគំនិត។ ក្រោយមក នៅប្រទេសជប៉ុនគេបិទមិនឲ្យប្រកាសដំណឹងល្អ គេបណ្តេញសាសនទូតទាំងអស់ នៅសល់តែគ្រីស្តបរិស័ទជប៉ុនមួយចំនួន។ អ្នកដែលបដិសេធជំនឿដោយព្រមជាន់រូបព្រះនាងម៉ារី រូបព្រះយេស៊ូ ព្រះឈើឆ្កាង រដ្ឋអំណាចឲ្យរួចជីវិត ប៉ុន្តែបើគេមិនព្រមបដិសេធជំនឿលើព្រះយេស៊ូទេ រដ្ឋអំណាចនឹងសម្លាប់គេ។ នៅក្នុងរដូវរងា រដ្ឋអំណាចបានឲ្យប៉ូលមីគីនិងប្រជាជនជប៉ុនមួយចំនួន ធ្វើដំណើរពីអូសាកាដល់

ទីក្រុងណាហ្គាសាគីអស់១០០០គីឡូម៉ែត្រ នៅតាមផ្លូវគ្រប់ទីកន្លែងមានគេមើលងាយ មានគេវាយ មានគេស្អប់...។ ពេលទៅដល់ណាហ្គាសាគី រដ្ឋអំណាចបានឆ្កាងលោកប៉ូលមីគី និងសហការី២៥នាក់ផ្សេងទៀតនៅលើភ្នំ តែគេបានបន្តច្រៀងលើកតម្កើងព្រះជាម្ចាស់។ លោកប៉ូលមីគីបានលើកទឹកចិត្តដល់សហការីរបស់គាត់ថា យើងស្លាប់តែយើងស្លាប់សម្រាប់ព្រះជាម្ចាស់ គាត់បានលើកលែងទោសឲ្យអ្នកដែលបានឆ្កាងគាត់។ នេះជាសក្ខីភាពមួយ ដែលណែនាំឲ្យជនជាតិជប៉ុនពោរពេញដោយកម្លាំងនៅក្នុងជំនឿ ប៉ូលមីគី មុនគាត់ស្លាប់គាត់បាននិយាយថា "**គ្មានផ្លូវផ្សេងដើម្បីទទួលការសង្គ្រោះ មានតែព្រះយេស៊ូដែលយើងបានជ្រើសរើស ណែនាំឲ្យយើងទទួលជីវិតអស់កល្បជានិច្ច**"។ ជនជាតិជប៉ុនដែលបានទទួលជំនឿពីប្រ៉ាំងស្វ័រសាវីយេ គេបានថែរក្សាជំនឿនេះយ៉ាងច្បាស់លាស់ គេរត់ចូលក្នុងព្រៃនិងបានរៀបចំអាសនៈដើម្បីគោរពព្រះជាម្ចាស់។ គ្រប់ពេលដែលមានបុណ្យធំៗរបស់ព្រះសហគមន៍គេដឹង ដោយសារសាសនទូតបានបង្រៀនគេឲ្យមើលព្រះចន្ទហើយគេដឹង ពេលវេលាព្រះយេស៊ូប្រសូត ពេលវេលាព្រះយេស៊ូសោយទិវង្គត ពេលវេលាព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ដើម្បីអធិដ្ឋាននិងជួបជុំគ្នា។

២៥០ឆ្នាំក្រោយមក នៅពេលសាសនទូតត្រលប់មកវិញ គេបានរកឃើញគ្រីស្តបរិស័ទជនជាតិជប៉ុន១០០០០នាក់ ដែលបានបន្តជំនឿពីមរណសាក្សីគេ។ នៅក្នុងព្រៃ គេបានធ្វើពិធីជ្រមុជទឹក គេបានអធិដ្ឋាន ហើយបន្តជំនឿឲ្យគ្នារហូតមកដើម្បីថែរក្សាជំនឿពីជីដូនជីតា។ នេះជាសក្ខីភាពមួយយ៉ាងពិសេស ដោយសារគេបានទទួលជំនឿយ៉ាងច្បាស់លាស់ និងមានចិត្តស្មោះត្រង់ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ កាន់តាមក្រឹត្យវិន័យ និងមានសេចក្តីក្លាហាន សេចក្តីក្លាហាននេះ បានណែនាំឲ្យគេថែរក្សាការពារជំនឿនៅក្នុងទុក្ខលំបាក។

លោកយាយ ម៉ាស់ត្រូបាំង ជាជនជាតិបារាំង ដែលព្រះសហគមន៍ទទួលស្គាល់ថាជាអ្នកបម្រើរបស់ព្រះជាម្ចាស់ដ៏ជាទីគោរព។ លោកយាយធ្លាប់និយាយថា "**នៅក្នុងទុក្ខលំបាកយើងរកឃើញពន្លឺនៃជំនឿ នៅក្នុងទុក្ខលំបាកយើងរកឃើញសេចក្តី នៅក្នុងទុក្ខលំបាកសេចក្តីស្រឡាញ់របស់យើងរីកចម្រើន**"។ នៅពេលយើងនឹកឃើញ ដល់មរណសាក្សីនិងគ្រីស្តនៅប្រទេសជប៉ុនពីដើម និងអ្វីដែលលោកយាយ ម៉ាស់ត្រូបាំង និយាយដូចជាចូលគ្នាណាស់ នៅក្នុងទុក្ខលំបាកនិងការឈឺចាប់ជំនឿរបស់យើងទៅជាពន្លឺ នៅក្នុងទុក្ខលំបាកនិងការឈឺចាប់សេចក្តីសង្ឃឹមរបស់យើងរឹងមាំ នៅក្នុងទុក្ខលំបាកនិងការឈឺចាប់សេចក្តីស្រឡាញ់របស់យើងរីកចម្រើន។ លោកយាយ ម៉ាស់ត្រូបាំង នេះមានជីវិតពិសេសគាត់មានជំនឿរឹងមាំ នៅពេលគាត់អាយុ១៥ឆ្នាំគាត់មានជំងឺស្ពឹកជើងស្ពឹកដៃ អាយុ២០ឆ្នាំគាត់ស្ពឹកកាន់តែខ្លាំងឡើងៗ អាយុ៣០ឆ្នាំគាត់នៅលើគ្រែដើរមិនរួចចាប់ផ្តើមខ្វាក់ភ្នែក។ ពីគាត់មានអាយុ៣០ឆ្នាំរហូតដល់អាយុ៨០ឆ្នាំ គាត់អត់ញ៉ាំទឹកនិង

អត់ញ៉ាំម្ហូបអាហារសោះ គាត់ទទួលតែព្រះកាយព្រះគ្រីស្តពីរដងក្នុងមួយសប្តាហ៍ គាត់ស្លាប់នៅឆ្នាំ១៩៨០។ រយៈពេល៥០ឆ្នាំគាត់រស់នៅក្នុងភាពងងឹត ប៉ុន្តែស្មារតីរបស់គាត់ ការអធិដ្ឋានរបស់គាត់ស្ថិតស្ថេររហូត ជំនឿរបស់គាត់រឹងមាំណាស់។ រៀងរាល់ថ្ងៃសុក្រគាត់ភ្ជាប់ជាមួយព្រះយេស៊ូមែនទែន មានឈាមដែលហូរពីដៃនិងថ្ងាសរបស់គាត់ ដូចជាគាត់បានភ្ជាប់ជាមួយទុក្ខលំបាករបស់ព្រះយេស៊ូ ដែលសោយទិវង្គតលើឈើឆ្កាង។ មួយខែម្តង មារសាតាំងមករំខានគាត់ឲ្យគាត់ធ្លាក់ពីលើគ្រែជាច្រើនដង គាត់ទទួលកម្លាំងតែពីព្រះកាយមួយអាទិត្យ២ដង។ កម្លាំងដែលគាត់មានណែនាំឲ្យជំនឿរបស់គាត់រឹងមាំទៅៗ មានគេមកពីប្រទេសជាច្រើនដើម្បីស្តាប់ការអប់រំគាត់អំពីបញ្ហាជីវិតរបស់គេ។ ពេលគេជួបគាត់ គេនិយាយអំពីបញ្ហារបស់គេខ្លីៗតែគាត់យល់ភ្លាម គាត់បានបំភ្លឺគេដើម្បីឲ្យគេទៅមុខនៅក្នុងជីវិតរបស់គេ។

រហូតដល់សព្វថ្ងៃ នៅក្នុងពិភពលោកមានផ្ទះសំណាក់ធម៌៧០កន្លែង ដែលព្រះជាម្ចាស់បានណែនាំឲ្យគាត់ធ្វើគឺផ្ទះនៃពន្លឺនិងសេចក្តីស្រឡាញ់។ គ្រីស្តបរិស័ទណា ដែលចង់រកឃើញជីវិតរបស់គេសាជាថ្មីនៅក្នុងព្រះជាម្ចាស់ គេមកផ្ទះសំណាក់ធម៌នេះ៦ថ្ងៃដោយមិននិយាយអ្វីសោះ ទទួលការអប់រំមួយថ្ងៃបួនដង ដើម្បីឲ្យជំនឿរីកចម្រើនសាជាថ្មី។ លោកយាយ ម៉ាស់ត្រូបាំង ធ្លាប់និយាយថា "**នៅក្នុងជីវិតរបស់យើងប្រហែលយើងមានឱកាសដើម្បីធ្វើការអស្ចារ្យ ការពិសេសបំផុតយ៉ាងតិចមែនទែន ប៉ុន្តែដើម្បីធ្វើអំពើល្អដ៏តូចតាចមួយយើងមានឱកាសច្រើនមែនទែន ហេតុនេះហើយយើងមិនត្រូវមានចិត្តលោភលន់ ដើម្បីធ្វើការអស្ចារ្យពិសេសនៅក្នុងពិភពលោកសព្វថ្ងៃនេះទេ ប៉ុន្តែឲ្យយើងមានចិត្តលោភលន់ដូចសន្តប៉ូល ដើម្បីធ្វើអំពើល្អដ៏តូចតាចនៅក្នុងជីវិតប្រចាំ**"។ ខ្ញុំគិតថា ស៊ីនិងសន្តីតេរេសានៃព្រះកុមារយេស៊ូ ដែលណែនាំឲ្យយើងមើលឃើញនៅក្នុងជីវិតសាមញ្ញធម្មតា វត្តមាននិងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់នៅកន្លែងណា។ យើងធ្វើដូចម្តេច នៅក្នុងជីវិតធម្មតារបស់យើងដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដល់បងប្អូនឯទៀតៗ។ ប្រសិនបើ យើងរស់របៀបនេះបន្តិចម្តងៗជីវិតរបស់យើងអាចភ្ជាប់នឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ថែមទៀត។ សូមមានចិត្តស្មោះត្រង់ សូមប្រព្រឹត្តតាមព្រះហឫទ័យរបស់ព្រះអង្គ សូមកាន់តាមក្រឹត្យវិន័យ ដើម្បីទៅជាមនុស្សម្នាក់ដែលមានចិត្តក្លាហានសមជាមនុស្សដ៏ពេញលក្ខណៈ។

យើងមានសន្តសន្តីយ៉ាងច្រើន ណែនាំឲ្យយើងទៅមុខនៅក្នុងជីវិតជាបុត្រធីតារបស់ព្រះជាម្ចាស់ ដើម្បីរកឃើញផ្លូវនៅក្នុងពិភពលោក នៅក្នុងដួងចិត្ត នៅក្នុងសង្គមយើងបច្ចុប្បន្ននេះ។ ការស្វែងរកព្រះជាម្ចាស់នេះជាជំនឿរបស់យើង រកឃើញព្រះជាម្ចាស់នេះជាសេចក្តីសង្ឃឹមរបស់យើង ទទួលស្គាល់វត្តមានរបស់ព្រះជាម្ចាស់នេះជាសេចក្តីស្រឡាញ់ដែលយើងមាននៅក្នុងជីវិត

មានអារម្មណ៍អំពីវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងជីវិតយើង ណែនាំឲ្យយើងមានសេចក្តីសុខដ៏ពេញលក្ខណៈ ភ្លក់រស់ជាតិរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង នេះជាអំណរសប្បាយដ៏ពេញលក្ខណៈណែនាំឲ្យយើងរីកចម្រើន នៅក្នុងជីវិតរបស់យើងជាបុត្រធីតារបស់ព្រះជាម្ចាស់។

ដូច្នេះ តាមរយៈមរណសាក្សីនៅប្រទេសជប៉ុន តាមរយៈម៉ាស់ត្រូបាំង យើងទូលអង្វរព្រះជាម្ចាស់សម្រាប់ព្រះសហគមន៍របស់យើងនៅប្រទេសកម្ពុជា ជាពិសេសភូមិភាគភ្នំពេញឲ្យការត្រាស់ហៅរបស់ព្រះអង្គ យាងចូលយ៉ាងជ្រៅនៅក្នុងជីវិត។ ដោយដឹងថា នៅពេលយើងតស៊ូ នៅពេលយើងមានទុក្ខលំបាក ជំនឿរបស់យើងបំភ្លឺយើងជានិច្ច នៅពេលយើងតស៊ូ នៅពេលយើងមានទុក្ខលំបាក សេចក្តីសង្ឃឹមរបស់យើងរឹងមាំទៅៗ នៅពេលយើងតស៊ូ នៅពេលយើងមានទុក្ខលំបាក សេចក្តីស្រឡាញ់របស់យើងរីកចម្រើនអស់កល្បជានិច្ច។ យើងទូលអង្វរព្រះជាម្ចាស់និងអរព្រះគុណព្រះអង្គ ដែលធ្វើដំណើរជាមួយយើង ដែលធ្វើជាគំរូ ដើម្បីឲ្យជីវិតរបស់យើងទៅមុខតទៅទៀត។ អាម៉ែន៕